**គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)**

Committee For Free And Fair Elections In Cambodia (COMFREL)

ខុមហ្វ្រែល COMFREL

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org

**គណៈកម្មាធិការនាយក**
**BOARD OF DIRECTORS**

លោក **ធន សារាយ**
**Mr. THUN SARAY**
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន **ADHOC**

លោក **សុក សំអឿន**
**Mr. SOK Sam Oeun**
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក **CDP**

លោក **យឹម ប៉ូ**
**Mr. YIM Po** អគ្គលេខាធិការ
និង នាយក **CCPCR**

កញ្ញា **ស៊ុន ចាន់សែន**
**Miss. SUN Chansen**
ប្រធាន **KYA**

លោក **មុំ សារិន**
**Mr. MOM Sarin**
នាយក **HRCDO**

លោកស្រី **ពឹង យក់ហៀប**
**Mr. PEUNG Yok Hiep**
នាយិកា **LAC**

លោកស្រី **ទីវ សារាយេត**
**Ms. TIV Sarayet**
សហនាយិកា **WMC**

កញ្ញា **សយ សារា វឌ្ឍនី**
**Miss. SAY Sara Vathany**
នាយិកា **CWCC**

លោក **គីម សុវណ្ណ**
**Mr. KIM Sovann**
នាយក **VIGILANCE**

លោក **អាង ច័ន្ទឫទ្ធិ**
**Mr. ANG Chanrith**
នាយក **KKKHRO**

លោក **យង់ គិមអេង**
**Mr. YONG Kim Eng**
នាយក **PDP-Center**

លោក **ភួង សិទ្ធិ**
**Mr. PHUONG Sith**

លោក **សឺន សែត**
**Mr. SEN Set**

ស.ប្រ.ក.៧/លេខ ១៩/០៩ គ.ប.ស.យ/អ.ក

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលសិក្ខាសាលាម្ចាស់ឆ្នោតក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍[១] នៃវិស័យអាទិភាពក្នុងខេត្ត ពោធិ៍សាត់

*ភ្នំពេញ, ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០០៩*

ប្រជាពលរដ្ឋប្រមាណ ៩០នាក់ មកពីស្រុកនានា និងក្រុងពោធិ៍សាត់ ក្នុងខេត្តពោធិ៍សាត់ និងមានសិក្ខាកាមស្ត្រី ចូលរួមប្រមាណ ៣៤% បានជួបជុំគ្នានៅក្នុងសិក្ខាសាលាម្ចាស់ឆ្នោត ក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តពោធិ៍សាត់ ដើម្បីពិភាក្សា និងកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តពោធិ៍សាត់ កាលពីថ្ងៃទី ០២ ខែតុលា ឆ្នាំ ២០០៩។

អភិបាលរងខេត្តពោធិ៍សាត់ លោក **ពេជ ហាន** បានមានមតិបើកសិក្ខាសាលាថា ប្រជាពលរដ្ឋបន្ទាប់ពីកំណត់លក្ខខណ្ឌសន្ទស្សន៍ហើយ ត្រូវធ្វើការតាមដានទៅលើលក្ខខណ្ឌសន្ទស្សន៍ទាំងនោះដើម្បីកំណត់ក្នុងការជ្រើសរើសតំណាងរបស់ខ្លួន នៅក្នុងមណ្ឌលរបស់ខ្លួននាពេលខាងមុខ ។

ឯកឧត្តម **ងួន ប៉ោសេង** សមាជិកក្រុមប្រឹក្សាខេត្តពោធិ៍សាត់បានលើកឡើងថា *"អ្វីដែលប្រជាពលរដ្ឋបានលើកឡើងគឺឃើញថាល្អច្រើន,,,,,រដ្ឋាភិបាលយកអ្វីដែលជាសំណូមពរដើម្បីធ្វើការសិក្សា និងអនុវត្ត,,,,,រាល់សំណូមពររបស់ប្រជាពលរដ្ឋគឺសុទ្ធតែជាអនុសាសន៍ល្អៗសំរាប់រាជរដ្ឋាភិបាលអនុវត្ត ហើយបើអនុវត្តបានតែ ៧០% ក៏បានល្អប្រសើរដែរ "* ។

លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំង១០ ដែលបានកំណត់ដោយម្ចាស់ឆ្នោតក្នុងខេត្តពោធិ៍សាត់រួមមាន:

| **លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអទិភាពនាំងជប់នៅក្នុងខេត្ត ពោធិ៍សាត់** |
|---|
| ១) - ស្ពានប្រឡាយពីក្បាលហុង(ឃុំរំលាល) ស្រុកកណ្តៀងទៅស្រុកបាកាន ១ ខ្សែ ដោយចាប់ផ្តើមពីឆ្នាំ ២០១០ដល់ឆ្នាំ ២០១៣ ។<br>- ស្ពានប្រឡាយ ២ខ្សែ ចាប់ពីសង្កាត់ផ្ទះព្រៃទៅ ឃុំស្វាយដូនកែវ ស្រុកបាកាន និងមួយកន្លែងទៀតនៅ ភូមិប្រឡាយធំ សង្កាត់ព្រៃញី ទៅដល់ស្រុកក្រគរខេត្តពោធិ៍សាត់ ដោយចាប់ផ្តើមកសាងចាប់ពី ឆ្នាំ ២០១០ ដល់ ២០១២ និងស្ពានប្រឡាយនេះក្នុងរយៈពេល ២ឬ ៣ឆ្នាំម្តង។ |

---

[១] ការសន្យាណាដែលមានសូចនាករច្បាស់លាស់-អាចមានជាក់ស្តែង អាចវាស់បានដូចជាការអនុម័តច្បាប់ ការបង្កើតស្ថាប័ន ឬជាសកម្មភាព ការអនុវត្តអ្វីមួយច្បាស់លាស់ ដោយមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬមួយប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់។

| |
|---|
| ២) សុំអោយរដ្ឋសភាអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ ហើយអោយមានប្រសិទ្ធិភាពក្នុងការអនុវត្តច្បាប់ប្រឆាំងអំពើពុករលួយ អោយបាន ១០០% អោយបាននៅចុងឆ្នាំ ២០០៩ ។ |
| ៣) - សុំបញ្ចុះតំលៃសេវាព្យាបាលនៅមន្ទីរពេទ្យខេត្តពោធិ៍សាត់ទាំងអស់(សំរាប់រដ្ឋ)៥០%នៃតំលៃបច្ចុប្បន្ន<br>- សុំអោយបុគ្គលិកពេទ្យប្រចាំការ២៤ម៉ោង ហើយបុគ្គលិកនីមួយៗត្រូវមានអាកប្បកិរិយារួសរាយរាក់ទាក់ មិនរើសអើង ចំពោះអ្នកជំងឺក្រីក្រ ។ មានរថយន្តសង្គ្រោះបន្ទាន់ដោយឥតគិតថ្លៃ (គ្រប់ស្រុកទាំងប្រាំមួយ) នៅគ្រប់មណ្ឌលសុខភាពស្រុក និងបុគ្គលិកសុខាភិបាលនៅតាមមូលដ្ឋានត្រូវមានជំនាញវិជ្ជាជីវៈពិតប្រាកដ ចាប់ពីឆ្នាំ ២០១០នេះតទៅ ។ |
| ៤) ស្នើសុំពេលដែលវារីអគ្គិសនីខេត្តពោធិ៍សាត់ដំណើរការ សុំអោយតំលៃអគ្គិសនី ១ គីឡូវ៉ាត់ម៉ោង ក្រោមតំលៃ ១០០០រៀល ។ |
| ៥) សុំអោយស្ថាប័នតុលាការខេត្តពោធិ៍សាត់ ចាត់វិធានការដោះស្រាយរាល់បណ្តឹងរបស់ប្រជាពលរដ្ឋអោយបានឆាប់រហ័សទៅតាម នីតិវិធីច្បាប់ប្រកបដោយភាពយុត្តិធម៌អោយបាន១០០%ដោយមានការ ទទួលស្គាល់ ទាំងភាគីចាញ់ និងភាគីដែលឈ្នះ អោយបាន ចាប់ពីពេលនេះតទៅ ។ |
| ៦) គ្រប់មណ្ឌលសុខភាព និងមន្ទីរពេទ្យក្នុងខេត្តពោធិ៍សាត់ កុំយកប្រាក់មុនការព្យាបាលនិងបន្ថយតំលៃសេវាមក ត្រឹម៣០% នៃតំលៃបច្ចុប្បន្ន ចាប់ពីពេលនេះតទៅ ។ |
| ៧) សុំពូជស្រូវទិន្នផលខ្ពស់ (ស្រូវសុម៉ាលីប៊ុនរ៉ានីហ៊ុនសែន) ដែលក្នុង ១ ឆ្នាំ ធ្វើបាន ២ ដង អោយគ្រប់កសិករក្រីក្រ ក្នុង ១ គ្រួសារ ២៥គីឡូក្រាម នៅទូទាំងខេត្តពោធិ៍សាត់អោយ បានចាប់ពីខែ ១ ឆ្នាំ ២០១០ |
| ៨) សុំបង្កើតសាលាសកលវិទ្យាល័យ(រដ្ឋ)ស្ថិតនៅក្រុងពោធិ៍សាត់ ចំនួន ១ខ្នង ពីរជាន់ មាន ៣០បន្ទប់ ហើយមានឧបករណ៍ (សំភារៈសិក្សា) ប្រើប្រាស់គ្រប់គ្រាន់ ចាប់ផ្តើមកសាងពីឆ្នាំ ២០១០ និងបញ្ចប់នៅឆ្នាំ ២០១១ ព្រមទាំងបង្កើតមជ្ឈមណ្ឌល បង្ហាត់ការងារដើម្បីធានាដល់សិស្ស-និស្សិតនៅពេលបញ្ចប់ការសិក្សា ត្រូវឱ្យមានការងារធ្វើ ។ |
| ៩) សុំតំលើងប្រាក់បៀវត្សគ្រូបង្រៀននៅខេត្តពោធិ៍សាត់គ្រូបឋមសិក្សាដល់វិទ្យាល័យបន្ថែម ៥០%នៃប្រាក់ខែបច្ចុប្បន្ន ចាប់ពី ដើមឆ្នាំ ២០១០តទៅ ។ ផ្តល់ប្រាក់លើកទឹកចិត្តសំរាប់គ្រូប្រជុំជនអោយបាន ៥០%នៃប្រាក់ខែបច្ចុប្បន្ន និង បន្ថែម ១០០%នៃប្រាក់ លើកទឹកចិត្តបច្ចុប្បន្នសំរាប់គ្រូនៅតំបន់ដាច់ស្រយាល ។ |
| ១០) សូមបញ្ឈប់ការស៊ីសំណូកគ្រប់រូបភាពក្នុងប្រព័ន្ធយុត្តិធម៌គ្រប់ស្ថាប័នដែលពាក់ព័ន្ធនិងប្រព័ន្ធយុត្តិធម៌ក្នុងខេត្តពោធិ៍សាត់អោយ បាន១០០% (ស្ថាប័នពាក់ព័ន្ធ តុលាការ ប៉ូលីស ប៉េអឹម ជលផល រដ្ឋបាលព្រៃឈើ ស្ថាប័នគយ) ដោយចាប់អនុវត្ត ចាប់ពីពេលនេះ តទៅ ។ |

សិក្ខាសាលានេះត្រូវបានរៀបចំឡើងដោយគណៈកម្មាធិការខុមហ្វ្រែល សហការជាមួយអង្គការរក្សាការពារសិទ្ធិមនុស្សនៃកម្ពុជា (VIGILANCE), សមាគមការពារសិទ្ធិមនុស្សនិងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC), សមាគមអភិវឌ្ឍន៍ពុទ្ធសាសនា (BDASE), , សមាគមទ្រទ្រង់កសិករជនបទខេត្តពោធិ៍សាត់ (SARF), សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស (LICADHO) ដែលក្នុងនោះមានការចូលរួមពីម្ចាស់ឆ្នោត ដែលតំណាងឱ្យសហគមន៍ អង្គការមិនមែនរដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/ និស្សិត កសិករ មកពីស្រុកភ្នំក្រវាញ ស្រុកកណ្តៀង ស្រុកក្រគរ ស្រុកបាកាន និងក្រុងពោធិ៍សាត់ នៅក្នុងខេត្តពោធិ៍សាត់ ។

សិក្ខាសាលាម្ចាស់ឆ្នោតនេះ ជាគំនិតបង្កើតថ្មីមួយក្នុងគោលបំណងឱ្យប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត នៅតាមមណ្ឌលនីមួយៗ:

១) មានការយល់ដឹងពីកម្មវិធីនយោបាយនិងយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាលជាប់ឆ្នោតឆ្នាំ ២០០៨
២) ចូលរួមក្នុងការកំណត់លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានា ដែលត្រូវការចាំបាច់ក្នុងមណ្ឌល (ខេត្ត) របស់ខ្លួន
៣) និង លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពនានាសម្រាប់មណ្ឌលនីមួយៗ ត្រូវបានចងក្រងជារបាយការណ៍ ដែលអាចឱ្យសិក្ខាកាមងាយចងចាំដើម្បីចូលរួមតាមដាន និងជម្រុញការអនុវត្តរបស់រាជរដ្ឋាភិបាល អ្នកតំណាងរាស្ត្រ ក្រុមប្រឹក្សា/គណៈអភិបាលខេត្ត-រាជធានី ក្នុងការសម្រេចបានលក្ខខណ្ឌសន្ទស្សន៍នៃវិស័យ ទាំងនោះ។

*សម្រាប់ព័ត៌មានបន្ថែមៗសូមទាក់ទង:*


- លោក **ចំនួ ដារិទ្ធ** អ្នកសម្របសម្រួលផ្នែកព័ត៌មានខុមហ្វ្រែល ទូរស័ព្ទ: ០១២ ៨៤៦ ២១១
- លោក **សុខ ពិទូរ្យ** អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទ: ០៨៩ ៥២៥ ៤៤៦